# សេក្ខិយវត្ត

## ( សម្រាប់សូត្រ )

ផ្សាយចេញពីវត្តនិគ្រោធវ័ន "គល់ទទឹង" ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌមានជ័យ រាជធានីភ្នំពេញ

ប្រមូលរៀបរៀងដោយ
ខ្ញុំព្រះករុណា អាត្មាភាព
សាមណេរ មនោរថ យ៉ុង តារា

# សេក្ខិយវត្ត ៧៥

(សម្រាប់សូត្រ)

ផ្សាយចេញពីសមាគមន៍ធម្មទាន ព្រះធម្មាចារ្យ មនោរថ យ៉ូន តារា
នាវត្តអង្គពណ្ណរាយណ៍ ភូមិប្រជុំអង្គ ឃុំជើងកើប ស្រុកកណ្ដាលស្ទឹង
ខេត្តកណ្ដាល


*ប្រមូលរៀបរៀងដោយ*

*ខ្ញុំព្រះករុណា អាត្មាភាព*

*សាមណេរ* **មនោរថ យ៉ូន តារា**


ព.ស.២៥៥៧ គ.ស.២០១៣

# អារម្ភកថា

សៀវភៅ"សេក្ខិយវត្ត"នេះគឺជាវត្តដែលភិក្ខុសាមណេរ ក្នុងសាសនមណ្ឌលត្រូវបដិបត្តិ ដែលព្រះពុទ្ធជាម្ចាស់បាន បញ្ញត្តិទុកហើយ ម្លោះហើយទើបលោកម្ចាស់ **ថន វណ្ណី** អារធនាឲ្យខ្ញុំព្រះករុណាអាត្មាភាពដកសង់ប្រមូលរៀបរៀង ឡើងនូវសៀវភៅនេះព្រោះថា ឃើញលោកអ្នកបួសហើយ ថ្មីៗដែលមិន ទាន់បានសិក្សានូវព្រះពុទ្ធវចនៈដែលជាកុ-លបុត្ត ប្រាថ្នារួចផុតអំពីទុក ។

ខ្ញុំព្រះករុណាធ្វើកូនសៀវភៅនេះមានបំណងចង់ឲ្យ ព្រះករុណាគុណម្ចាស់ទន្ទេញឲ្យរត់មាត់ងាយស្រួលនឹង បដិបត្តិ ហើយសៀវភៅនេះសោតអាចយកដាក់ខ្លួនបាន ។

មួយម្យ៉ាងទៀតបុណ្យឯណាដែលខ្ញុំព្រះករុណាខ្វាយ-ខ្វល់បំពេញក្នុងសាសនានេះ ខ្ញុំសូមឧទ្ទិសបុណ្យនោះ ដល់

ពពួកញាតិរបស់ខ្ញុំមានមាតាបិតា ជាដើម ដល់គ្រូឧបជ្ឈាយាចារ្យផង ដល់សត្វលោក ផង សូមឲ្យអ្នកទាំងអស់នោះបានដល់នូវសេចក្ដីសុខចុះ ។

**វត្តអង្គពណ្ណរាយណ៍**

ថ្ងៃអង្គារ ១៥រោច ខែមិគសិរ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស.២៥៥៧

ត្រូវនឹងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣

សាមណេរ **មនោរថ យ៉ូន តារា**

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**
វីកិរិយានមស្សការថ្វាយបង្គំនៃខ្ញុំព្រះករុណាចូលមាន ដល់ព្រះដ៏មានព្រះភាគអង្គនោះ ព្រះអង្គជាព្រះអរហន្តដ៏ប្រសើរ ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមាន គ្រូអាចារ្យណា ប្រដៅព្រះអង្គឡើយ ។

**ឥមេ ខោ បនាយស្មន្តោ (បញ្ច សត្តតិ) សេក្ខិយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។** បពិត្រលោកអ្នកមានអាយុទាំងឡាយ! វត្តដែលគប្បី សិក្សាទាំងឡាយ(ចិតសិបប្រាំ)នេះឯង មកកាន់ឧទ្ទិស (គឺការសម្តែងឡើង) ។

**១) បរិមណ្ឌលំ និវាសេស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អា-

ត្មាអញនឹងស្លៀក (ស្បង់) ឲ្យជាបរិមណ្ឌល ។ (បិ.៤,ទំ.៤៣៥)

**២) បរិមណ្ឌលំ បារុបិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដីសិក្សា អាត្មាអញនឹងដណ្ដប់ (គឺគ្រង) ចីពរឲ្យជាបរិមណ្ឌល ។

**៣) សុប្បដិច្ឆន្នោ អន្តរឃរេ គមិស្សាមីតី សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដីសិក្សា អាត្មាអញនឹងបិទបាំងកាយ (គឺឃ្លុំ) ឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ។

**៤) សុប្បដិច្ឆន្នោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដី

សិក្សា អាត្មាអញនឹងបិទបាំងកាយ (គឺឃ្លុំ) ឲ្យល្អ អង្គុយក្នុងចន្លោះផ្ទះ ។

**៥) សុសំវុតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករ-ណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សា អាត្មាអញនឹង សង្រួមឲ្យល្អ ដើរទៅក្នុងចន្លោះផ្ទះ ។

**៦) សុសំវុតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សា អាត្មាអញនឹង សង្រួមឲ្យល្អ អង្គុយក្នុងចន្លោះផ្ទះ ។

**៧) ឱក្ខិត្តចក្ខុ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករ-ណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សា

អាត្មាអញនឹង មានភ្នែកសំឡឹងចុះ ដើរទៅក្នុចន្លោះផ្ទះ ។

**៨) ឱក្ខិត្តចក្ខុ អន្តរឃរេ និសីទិស្សាមីតី សិក្ខា ក-រណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ នឹងមានភ្នែកសំឡឹងចុះ អង្គុយក្នុងចន្លោះផ្ទះ ។

**៩) ន ឧក្ខិត្តកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខាករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសើយចីវរ ដើរទៅក្នុងចន្លោះផ្ទះ ។

**១០) ន ឧក្ខិត្តកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសើយចីវរ អង្គុយក្នុងចន្លោះផ្ទះ ។

**បរិមណ្ឌលវគ្គោ បឋមោ ។** បរិមណ្ឌលវគ្គទី ១ (ចប់)

**១១) ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ។

**១២) ន ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តី

សិក្សាថា អាត្មាអញនឹងមិនសើចខ្លាំង អង្គុយក្នុងចន្លោះផ្ទះ ។

១៣) **អប្បសទ្ទោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងនិយាយសម្លេងតិច ដើរទៅក្នុងចន្លោះផ្ទះ ។

១៤) **អប្បសទ្ទោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងនិយាយសម្លេងតិច អង្គុយក្នុងចន្លោះផ្ទះ ។

**១៥) ន កាយប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនគ្រលែងកាយ ដើរទៅក្នុងចន្លោះផ្ទះ ។

**១៦) ន កាយប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនគ្រលែងកាយ អង្គុយក្នុងចន្លោះផ្ទះ ។

**១៧) ន ពាហុប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនបង់បោយ ដើរទៅក្នុងចន្លោះផ្ទះ ។

**១៨) ន ពាហុប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆ្កាវដៃ អង្គុយក្នុងចន្លោះផ្ទះ ។

**១៩) ន សីសប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនអង្រួនក្បាល ដើរទៅក្នុងចន្លោះផ្ទះ ។

**២០) ន សីសប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនអង្រួនក្បាល អង្គុយក្នុងចន្លោះផ្ទះ ។

**ឧជ្ជគ្ឃិកវគ្គោ ទុតិយោ ។** ឧជ្ជគ្ឃិកវគ្គទី ២(ចប់)

**២១) ន ខម្ភកតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ក-រណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនយកដៃស្ទឹមចង្កេះ ដើរទៅក្នុងចន្លោះផ្ទះ ។

**២២) ន ខម្ភកតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខាករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនយកដៃស្ទឹមចង្កេះ អង្គុយក្នុងចន្លោះផ្ទះ ។

**២៣) ន ឱគុណ្ឋិតោ អន្តរឃរេ គមិស្សាមីតិ សិក្ខាករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សា

ថា អាត្មាអញនឹងមិនទទូរក្បាល ដើរទៅក្នុងចន្លោះផ្ទះ ។

**២៤) ន ឱគុណ្ឋិតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនទទូរក្បាល អង្គុយក្នុងចន្លោះផ្ទះ ។

**២៥) ន ឧក្កុដិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនចំអើតជើង ដើរទៅក្នុងចន្លោះផ្ទះ ។

**២៦) ន បល្លត្ថិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនអង្គុយត្របោមក្បាលជង្គង់ ក្នុងចន្លោះផ្ទះ ។

**ឆព្វីសតិ សារុប្បា ។** (ចប់) សារុប្បម្ភៃប្រាំមួយ ។

**២៧) សក្កច្ចំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងទទួលអាហារបិណ្ឌបាត ដោយគោរព ។

**២៨) បត្តសញ្ញី បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តី

សិក្សាថា អាត្មាអញនឹងសម្គាល់តែក្នុងបាត្រ ទទួលបិណ្ឌបាត ។

**២៩) សមសូបកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងទទួលបិណ្ឌបាត ឲ្យល្មមគ្នានឹងសម្ល ។

**៣០) សមតិត្តិកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងទទួលបិណ្ឌបាត ឲ្យស្មើត្រឹមកណ្តាប់មាត់បាត្រ ។

**ខន្ធកវគ្គោ តតិយោ ។** ខន្ធកវគ្គទី ៣(ចប់) ។

**៣១) សក្កច្ចំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករ-ណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងឆាន់បិណ្ឌបាត ដោយគោរព ។

**៣២) បត្តសញ្ញី បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងសម្គាល់តែក្នុងបាត្រឆាន់បិណ្ឌបាត ។

**៣៣) សបទានំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករ-ណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងឆាន់បិណ្ឌបាត រាចឲ្យស្មើ ។

**៣៤) សមសូបកំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងឆាន់បិណ្ឌបាតឲ្យល្មមគ្នានឹងសម្ល ។

**៣៥) ន ថូបតោ ឱមទ្ទិត្វា បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនច្រមត្រង់កំពូលបាយហើយឆាន់បិណ្ឌបាត ។

**៣៦) ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេ-ស្សាមិ ភិយ្យោ កម្យកំ ឧបាទាយាតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនកកាយបាយលុបសម្ល ឬម្ហូប ព្រោះអាស្រ័យសេចក្តីល្មោភច្រើន ។

**៣៧) ន សូបំ វា ឱទនំ វា អគ្គិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញឥតមានជម្ងឺ នឹងមិនសូមសម្ល ឬបាយដើម្បីប្រយោជន៍ខ្លួនឯងហើយឆាន់ ។

**៣៨) ន ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនប្រុងលើទោសហើយសម្លឹងមើលបាត្រពួកភិក្ខុដទៃ ។

**៣៩) នាតិមហន្តំ កពឡំ ករិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនធ្វើពំនូតបាយ ឲ្យធំពេក ។

**៩០) បរិមណ្ឌលំ អាលោបំ ករិស្សាមីតិ សិក្ខា ករ-ណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងធ្វើពំនូតបាយ ឲ្យជាបរិមណ្ឌល គឺឲ្យមូល ។

**សក្កច្ចវគ្គោ ចតុត្ថោ ។** សក្កច្ចវគ្គទី ៤ (ចប់) ។

**៩១) ន អនាហដេ កពឡេ មុខទ្វារំ វិវរិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញកាលពំនូតបាយមិនទាន់មកដល់ នឹងមិនបើកទ្វារមាត់ចាំ ។

**៩២) ន ភុញ្ជមានោ សព្វំ ហត្ថំ មុខេ បក្ខិបិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដី

សិក្សាថា អាត្មាអញកាលឆាន់នឹងមិនញាត់ម្រាមដៃទាំងអស់ចូលទៅក្នុងមាត់ ។

៤៣) **ន សកពឡេន មុខេន ព្យាហរិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិននិយាយទាំងពំនូតបាយនៅក្នុងមាត់ ។

៤៤) **ន បិណ្ឌុក្ខេបកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់បោះដុំបាយទៅក្នុងមាត់ ។

**៩៥) ន កពឡាវច្ឆេទកំ ភុញ្ជិស្សាមីតិ សិក្ខា ករ-ណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់កាត់ពំនូតបាយ ។

**៩៦) ន អវគណ្ឌការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណី-យា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់បៀមពំនូតបាយនៅក្នុងថ្ពាល់ ។

**៩៧) ន ហត្ថនិទ្ធូនកំ ភុញ្ជិស្សាមីតី សិក្ខា ករណី-យា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់រលាស់ដៃ ។

**៤៨) ន សិត្ថាវការកំ ភុញ្ជិស្សាមីតិ សក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់ ធ្វើគ្រាប់បាយឲ្យជ្រុះរោយរាយ ។

**៤៩) ន ជីវ្ហានិច្ឆារកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់លៀនអណ្តាត ។

**៥០) ន ចបុចបុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់ធ្វើសូរឲ្យឮផ្ចប់ៗ ។

**កពឡវគ្គោ បញ្ចមោ ។** កពឡវគ្គទី៥(ចប់)

**៥១) ន សុរុសុរុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់ធ្វើសូរឲ្យឮគ្រូកៗ ។

**៥២) ន ហត្ថនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់លិទ្ធដៃ ។

**៥៣) ន បត្តនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិន ឆាន់កោស់បាត្រ ។

**៥៤) ន ឱដ្ឋនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណី-យា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់លិទ្ធបបូរមាត់ ។

**៥៥) ន សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គ-ហេស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើ សេចក្តីសិក្សាថា អាត្មាអញមានដៃប្រឡាក់ដោយអាមិស នឹងមិន ទទួលភាជនៈទឹកសម្រាប់ឆាន់ ។

**៥៦) ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេស្សា-មីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើ សេចក្តីសិក្សាថា អាត្មាអញនឹងមិនចាក់ទឹងលាងបាត្រទាំងគ្រាប់បាយក្នុងចន្លោះផ្ទះ ។

# សមត្ថឹស ភោជនប្បដិសំយុត្តា ។

(ចប់)ភោជនប្បដិសំយុត្ត៣០គត់ ។

**៥៧) ន ឆត្តបាណិស្ស អគិ្គលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដី សិក្សាថា អាត្មាអញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជម្ងឺមានឆត្រក្នុងដៃ ។

**៥៨) ន ទណ្ឌបាណិស្ស អគិ្គលានស្ស ធម្មំ ទេសិស្សាមីតិ សក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសម្ដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានដំបងក្នុងដៃ ។

**៥៩) ន សត្ថបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តី សិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺមាន គ្រឿងសស្ត្រាក្នុងដៃ ។

**៦០) ន អាវុធបាណិស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តី សិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺមាន គ្រឿងអាវុធក្នុងដៃ ។

**សុរុសុរុវគ្គោ ឆដ្ឋោ ។** សុរុសុរុវគ្គទី៦ (ចប់) ។

**៦១) ន បាទុការូឡ្ហស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បី

ធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ ពាក់ទ្រនាប់ជើង ។

**៦២) ន ឧបាហនារូឡ្ហស្ស អគិ្គលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ ពាក់ស្បែកជើង ។

**៦៣) ន យានគតស្ស អគិ្គលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ នៅលើយាន ។

**៦៤) ន សយនគតស្ស អគ្គិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ នៅលើដំណេក ។

**៦៥) ន បល្លត្ថិកាយ និសិន្នស្ស អគ្គិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយត្របោងក្បាលជង្គង់ ។

**៦៦) ន វេឋិតសីសស្ស អគ្គិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បី

ធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ ជួតក្បាល ។

**៦៧) ន ឱគុណ្ឋិតសីសស្ស អគិ្លានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺ ទទូរក្បាល ។

**៦៨) ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិ្លានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនអង្គុយផ្ទាល់នឹងផែនដី ហើយសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺអង្គុយលើអាសនៈ ។

**៦៩) ន នីចេ អសនេ និសីទិត្វា ឧច្ចេ អាសនេ និសន្នស្ស អគ្គិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនអង្គុយលើអាសនៈទាប ហើយសម្ដែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយលើអាសនៈខ្ពស់ ។

**៧០) ន ឋិតោ និសិន្នស្ស អគ្គិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឈរសម្ដែងធម៌ដល់មនុស្សគ្មានជម្ងឺដែលអង្គុយ ។

**៧១) ន បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគ្គិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។**

ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនដើរខាងក្រោយ ហើយសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺដើរខាងមុខ ។

៧២) **ន ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនដើរក្រៅផ្លូវ ហើយសម្តែងធម៌ដល់មនុស្សគ្មានជម្ងឺដើរតាមផ្លូវ។

## សោឡស ធម្មទេសនាបដិសំយុត្តា ។

(ចប់) ធម្មទេសនាបដិសំយុត្ត ១៦ ។

**៧៣) ន ឋិតោ អគិ្គលានោ ឧច្ចារំ វា បស្សាវំ វា ករិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញគ្មានជម្ងឺនឹងមិនឈរបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ។

**៧៤) ន ហរិតេ អគិ្គលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញគ្មានជម្ងឺនឹងមិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬក៏ស្តោះទឹកមាត់ដាក់លើស្មៅស្រស់ ឬឈើស្រស់ ។

**៧៥) ន ឧទកេ អគិ្គលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។** ភិក្ខុ(សាមណេរ) គប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញ

គ្មានជម្ងឺនឹងមិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬក៏ស្តោះទឹកមាត់ដាក់លើទឹក ។

**តយោ បកិណ្ណកា និដ្ឋិតា ។** ចប់ បកិណ្ណកៈ ៣ ។

**បាទុកាវគ្គោ សត្តមោ ។** បាទុកាវគ្គទី ៧ (ចប់) ។

**ឧទ្ទិដ្ឋា ខោ អាយស្មន្តោ (បញ្ចសត្តតិ) សេក្ខិយា ធម្មា ។ តត្ថាយស្មន្តេ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា? ទុតិយម្បិ បុច្ឆាមិ, កច្ចិត្ថ បរិសុទ្ធា? តតិយម្បិ បុច្ឆាមិ, កច្ចិត្ថ បរសុទ្ធា? បរិសុទ្ធេត្ថាយស្មន្តោ, តស្មា តុណ្ហី ។ ឯវមេតំ ធារយាមិ ។** បពិត្រលោកអ្នកមានអាយុទាំងឡាយ, វត្តដែលគប្បីសិក្សាទាំង(ចិតសិបប្រាំ)គឺខ្ញុំព្រះករុណាបានសម្តែងរួចហើយ ។ ខ្ញុំព្រះករុណាសូម

សួរលោក អ្នកមានអាយុទាំងឡាយ ក្នុងសេក្ខិយវត្ត ទាំងនោះ, លោកទាំងឡាយជាអ្នកបរិសុទ្ធិហើយឬ? ខ្ញុំព្រះករុណាសូមសួរជាគំរប់ពីរដងទៀត, លោក ទាំងឡាយជាអ្នកបរិសុទ្ធិហើយឬ? ខ្ញុំព្រះករុណាសូម សួរជាគំរប់បីដងទៀត, លោកទាំងឡាយជាអ្នក បរិសុទ្ធិហើយឬ? លោកអ្នកមានអាយុទាំងឡាយ សុទ្ធិតែជាអ្នកបរិសុទ្ធិក្នុងសេក្ខិយវត្តទាំងនុ៎ះហើយ, ព្រោះហេតុនោះបានជានៅស្ងៀម ។ ខ្ញុំព្រះករុណា សូមចាំទុកនូវហេតុនេះ ដោយកិរិយានៅស្ងៀមយ៉ាង នេះ ។

**សេក្ខិយា និដ្ឋិតា ។** ចប់ សេក្ខិយវត្ត ។

# អ្នកត្រួតពិនិត្យ

ភិក្ខុ **អ៊ិន ពិសី**

ភិក្ខុ **ហ៊ួន រ៉ា**

សាមណេរ **ហ៊ាន សុហៃ**

និងសមណសិស្សថ្នាក់បឋមវត្តនិគ្រោធវ័ន

**បរិច្ចាគថវិកាក្នុងការបោះពុម្ព**

ព្រះត្រៃបិដកវជ្ជី វជ៍ តុង

ព្រមទាំងពុទ្ធបរិស័ទ

## ធម្មទានដោយ

លោកម្ចាស់គ្រូ អ៊ិន ពិសី, ភិ.គឿន គុណ,ភិ. ហ៊ួន រ៉ា, សា. យ៉ូន តារា, សា.ផង់ សុផាត,សា. ជ័យ ហួត, សា. យ៉យ ហ៊ុល, សា. អ៊ុំ រិទ្ធី, សា. សាត់ ម៉េង ឡុង, សា. ប៉ុត បូរឹម, សា. ញ៉ៅ រ៉ាវី, សា. ផុង សឹងហេង, សា. វ៉ វុទ្ធី, សា. ណាក់ ចាន់រិទ្ធ, សា. ចយ សីហា, សា. បូ រតនា, សា. រត្ន សារ៉ាយ, សា. ណាង សុផានិត, សា. អ៊ុន ជ័យ, សា. យ័ន សារ៉ាត, សា. មិន សុជាតិ, សា. ឡុង វាសនា, សា. សុខ ប្រុស, សា. អាន សុណាត



សាមណេរ មនោរថ យ៉ុង គាក

កាសាវកណ្ឋា ពហវោ បាបធម្មា អសញ្ញតា
បាបា បាបេហិ កម្មេហិ និរយន្តេ ឧបបជ្ជរេ ។

ពួកជនច្រើននាក់ ដែលមានព័ទ្ធព័ន្ធ ដោយសំពត់កាសាវៈ
តែ (ប្រព្រឹត្ត) ធម៌លាមក មិនបានសង្រួម ពួកជនលាមកទាំងនោះ
រមែងទៅកើតក្នុងនរក ដោយសារកម្មទាំងឡាយដ៏លាមក ។

ទុកជាចំណងដៃមុនបែកគ្នា